ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២១

នៅក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៥លើក ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២០

២-ពិនិត្យ និងសម្រេចលើគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១

៣-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ រួមមាន៖

-សេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល

នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់ធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃ លើអានុភាព ១៩០មេហ្គាវ៉ាត់ ខេត្តកោះកុង

៤-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី២

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៩៥៣ច្បាប់

-បានសិក្សាស្រាវជ្រាវ និងផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់

- បានធ្វើកំណត់បង្ហាញព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន១៥២ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ, មន្ត្រីជំនាញការិយាល័យ អប់រំ យុវជន និងកីឡា ខណ្ឌចំការមន, និងមន្ត្រីរដ្ឋបាលខេត្តក្រចេះចំនួន០៣លើក ដើម្បីឈ្វេងយល់អំពីវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មចំនួន០៨លើក ដើម្បីសិក្សាឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់អភិបាលនៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទរបស់ខេត្ត មន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីរមុខងារសាធារណៈ និងបញ្ហាប្រឈមនានា នៅខេត្តកោះកុង, សិក្សាឈ្វេងយល់អំពីវឌ្ឍនភាពលើការងារភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ការងារបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រមូលព័ត៌មានបញ្ហាប្រឈម និងសំណូមពរផ្សេងៗ នៅខេត្តកណ្តាល, សិក្សាឈ្វេងយល់ពីបញ្ហាប្រឈមការបម្រើសេវាសាធារណៈ ការងារអត្រានុកូលដ្ឋាន និងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ

ព្រមទាំងតាមដានការសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់ អាស្រ័យផលយូរអង្វែងលើតំបន់ការពារធនធានធម្មជាតិ និងតំបន់របៀងអភិរក្សជីវចម្រុះ នៅខេត្តឧត្តរមានជ័យ, សិក្សាឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងប្រមូលព័ត៌មាន ផ្សព្វផ្សាយច្បាប់ តាមដានការអនុវត្តច្បាប់ ដោយផ្តោតលើបញ្ហាលើក កម្ពស់សមភាពយេនឌ័រ និងសុខភាពសាធារណៈ ការរស់នៅ និងការធ្វើការងារតាមគន្លងថ្មី ស្របតាមបរិបទកូវីដ-១៩ ព្រមទាំងសិក្សាឈ្វេងយល់អំពីវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ គណៈកម្មការ នៅខេត្តរតនគិរី ខេត្តកំពង់ចាម និងខេត្តតាកែវ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញ បេសកកម្មជាមួយប្រតិភូក្រសួងបរិស្ថាន ដើម្បីពិភាក្សាលើករណីប្រជាពលរដ្ឋដែលកាន់កាប់ និង អាស្រ័យផលនៅក្នុងដែនជំរកសត្វព្រៃភ្នំត្នោត និងភ្នំពក នៅឃុំស្ដៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំក្រុមអ្នកច្បាប់រាជធានីភ្នំពេញ និងក្រុមអ្នកច្បាប់មកពីខណ្ឌទាំង១៤ និងកិច្ចប្រជុំក្រុម ប្រឹក្សាជាតិ ព្រមទាំងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សា ថ្នាក់មូលដ្ឋានក្នុងគោលបំណងដើម្បីពិនិត្យមើលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ដែល សម្ព័ន្ធភាពជាតិបានអនុវត្តកន្លងមក ព្រមទាំងពិនិត្យ និងអនុម័តលើផែនការសកម្មភាពការងារ និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់

- បានតាមដានការងារកំណែទម្រង់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងសេដ្ឋកិច្ច កញ្ចប់ថវិកា ចំណូល-ចំណាយ និងបំណុលសាធារណៈចំនួន១០អត្ថបទ។

**៣- មុខងារតំណាង**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំពិភាក្សាការងាររវាង***សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា*** ជាមួយឯកឧត្តម ***ស៊ុន ចាន់ថុល*** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធា-រណការ និងដឹកជញ្ជូន ចំនួន០១លើក

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា ចុះបំពេញការងារ ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយចែកជូនអាជ្ញាធរ កងកម្លាំង ជាពិសេសប្រជាពលរដ្ឋក្រីក្រ ជួបការលំបាក ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៤២លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ ម៉ាស អាល់កុល និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ដើម្បី ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបាន បំពេញភារកិច្ចផ្សេងៗទៀតនៅមូលដ្ឋាន រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន ៧៩៩លើក

- បានសហការរៀបចំវេទិកាថ្នាក់ស្រុកចំនួន០២លើក នៅស្រុកកងមាស និងស្រុកកោះសូទិន ខេត្តកំពង់ចាម ស្តីពី ការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព និង ការអភិវឌ្ឍមូលដ្ឋាន និងបានរៀបចំពិធីសំណេះសំណាលចំនួន០១លើក នៅស្រុកវើនសៃ ខេត្តរតនគិរី ជាមួយប្រធានក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ ស្មៀនឃុំ សមាជិក ក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងអាជ្ញាធរស្រុក មានអ្នកចូលរួមសរុបចំនួន ១៩៦នាក់

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយទៅប្រគល់ជូនសង្កាត់ទាំង៩ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីទុកជូនអាជ្ញាធរសង្កាត់ ចែកជូនប្រជាពលរដ្ឋងាយរងគ្រោះចំនួន០៦លើក ព្រមទាំងនាំយក អំណោយ និងថវិកាមួយចំនួនឧបត្ថម្ភជូនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ដែលកំពុងធ្វើចត្តាឡីស័ក និងរស់នៅតំបន់ក្រហមចំនួន៣៣នាក់

- បានរៀបចំអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និងលោកជំទាវ ចែកជូនមន្ត្រីរាជការ និងកងកម្លាំងការពារសន្តិសុខសណ្តាប់ធ្នាប់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, សមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ, ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ចំនួន១,៥៩៩គ្រួសារ និងប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័កចំនួន៦៨៩នាក់ នៅមណ្ឌល ចំនួន០៦កន្លែង ក្នុងរាជធានីភ្នំពេញ

- បាននាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩

- បានឧបត្ថម្ភថវិកាមួយចំនួនជូនកាកបាទក្រហមកម្ពុជា និងក្រុមគ្រូពេទ្យដែលបានចាក់ វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ១៩ ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានទទួលពាក្យបណ្តឹងចំនួន២៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន១៩ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន១៩ករណី បញ្ជូនពាក្យបណ្តឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែនចំនួន០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១៩ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៧ករណី និងតម្កល់ទុកមិនចាត់ការចំនួន០៣ករណី ទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន០៦ករណី

- បានទទួលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៧០នាក់ ព្រមទាំងបានអនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន១៦ក្បាល និងសងវិញចំនួន០៧ក្បាល

- បានទទួលសៀវភៅពីអង្គការមូលនិធិអាស៊ីចំនួន២៧៧ក្បាល

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៣០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ កុមារកំព្រា និងជនក្រីក្រ

- បានផលិតទស្សនាវដ្តីប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ចំនួន៤,៨០០ក្បាល

- បានផលិតសៀវភៅបត់ស្តីពី មុខងារនីតិកម្មព្រឹទ្ធសភាចំនួន១,០០០ក្បាល

- បានធ្វើសាររំលែកទុក្ខជូនឥស្សរជននានាចំនួន១៥លើក

- បានធ្វើសារលិខិតថ្វាយព្រះពរសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជូនពរថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានាចំនួន៣៨លើក។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ និងអគ្គទូតនានាចំនួន០៥លើក

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលា ព្រមទាំងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានាចំនួន០៣លើក

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិនានា ចូលជួបសម្តែងការគួរសម និងជម្រាបលាចំនួន០៤លើក

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំអន្តរជាតិនានា (APF, APPF, IPU, AIPA, ASEP, ASGP)តាមប្រព័ន្ធវីដេអូ ចំនួន១២លើក

- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១នាក់ ចូលរួមវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិច ទទួលបន្ទុកសុខភាពពិភពលោក (APPFGH) តាមប្រព័ន្ធវីដេអូ

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការរវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងពិធីចុះហត្ថលេខាលើអនុស្សរណៈ(MOU)រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាជាមួយវិទ្យាស្ថានសភាអាស៊ី (PCA)

- បានរៀបចំពិធីជូនលោកជំទាវប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភា ទទួលគ្រឿងឥស្សរិយយសពីសាធារណរដ្ឋបារាំង

- បានរៀបចំបែបបទ និងទំនាក់ទំនងជាមួយលោកLee Jung-geun ប្រធានសហព័ន្ធសហគ្រាសធុនតូចប្រចាំកម្ពុជា ដើម្បីទទួលម៉ាសចំនួន៣៦៨,០០០ ជូនស្ថាប័នព្រឹទ្ធសភា

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន៦២ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ចំនួន០៦ច្បាប់

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិ និងនយោបាយចំនួន៤៣៣អត្ថបទ

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ស្ថានទូតចិន, ស្ថានទូតហ្វីលីពីន, ស្ថានទូតម៉ាឡេស៊ី, អគ្គលេខាធិការដ្ឋានរដ្ឋសភា,ទីស្តីការគណៈរដ្ឋមន្ត្រី, ដៃគូភាគីចិន, អង្គការមូលនិធិអាស៊ី, អង្គការចៃកា(JICA), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA), ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃ(Tica), ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច(CDC), មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), វិទ្យាស្ថានសាន់ហ៊យស៍, វិទ្យាស្ថានសភាអាស៊ី(PCA), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), សមាគមត្រាជូ, ក្រុមហ៊ុនKOHA, ក្រុមហ៊ុនCambodia Hosting និងក្រសួងស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាលព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- យោងតាមសារាចរណែនាំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំជាមួយគណៈកម្មការទី២ព្រឹទ្ធសភា ដើម្បីកាត់បន្ថយការចំណាយប្រតិបត្តិការ សំដៅចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងទប់ទល់ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានធ្វើបាឋកថាស្តីពី តួនាទី ភារកិច្ចព្រឹទ្ធសភាកម្ពុជា សមិទ្ធផល ការប្រឈម និងមាគ៌ាឆ្ពោះទៅកាន់សភាទំនើបជូនសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ និងសិស្សមន្ត្រីក្រមការជំនាន់ទី៩ និងកម្មសិក្សាការីទាំងអស់នៃសាលាភូមិន្ទរដ្ឋបាលចំនួន១,០០០នាក់តាមប្រព័ន្ធអនឡាញ

- បានទទួលលិខិតចូលចំនួន៤,៦៦៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១,៦៧៦ច្បាប់

- បានផលិតរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ (លើកទី១ និងទី២) ជូនសម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ ប្រកបដោយជោគជ័យ

- បានរៀបចំតារាងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩ ចំនួន០៨នាក់, ស្ថិតនៅជាប់តំបន់ក្រហមចំនួន១០១នាក់ និងកំពុងធ្វើចត្តាឡីស័កចំនួន០៩នាក់

- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- បានតាមដាន និងធ្វើបច្ចុប្បន្នភាពការប្រើប្រាស់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ របស់បណ្តាប្រទេសនានានៅលើពិភពលោកចំនួន១៥ច្បាប់

- បានស្រាវជ្រាវ និងផលិតឯកសារផ្សេងៗពាក់ព័ន្ធនឹងអាស៊ាន សេដ្ឋកិច្ច សង្គម បរិស្ថាន និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំនួន១៥ប្រធានបទ

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន

ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការចែកផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- បានប្រជុំរៀបចំផែនការការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីធានានិរន្តភាព និងប្រសិទ្ធភាពក្នុងបរិបទជំងឺកូវីដ-១៩

- បានប្រជុំកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP4) និងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រោមកម្មវិធី(PFM)

- បានប្រជុំពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០២១-២០២៣) និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២១

- បានប្រជុំគណៈកម្មការវាយតម្លៃស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការ, គោលការណ៍ផ្ដល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងគោលការណ៍គ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០២១

- បានធ្វើបច្ចុប្បន្នភាពគោលការណ៍គ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានផលិតខ្សែវីដេអូស្ដីពី ការអភិវឌ្ឍរយៈពេល១ឆ្នាំ ក្នុងឆ្នាំទី៣នៃព្រឹទ្ធសភា នីតិកាលទី៤

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានធ្វើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២០ និងរៀបចំគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

- បានរៀបចំយុទ្ធសាស្ត្រថវិកាព្រឹទ្ធសភា៣ឆ្នាំរំកិល (២០២២-២០២៤) និងគម្រោងថវិកាព្រឹទ្ធសភា ឆ្នាំ២០២២

- បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០២១ ជូនគណៈ-កម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានដេញថ្លៃការផ្គត់ផ្គង់ការបោះពុម្ព សម្ភារការិយាល័យ សម្ភារអនាម័យ និងឯកសណ្ឋាន

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំតបណ្តាញប្រព័ន្ធ(FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៥០៦ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន៨៦ប័ណ្ណ

- បានបែងចែកប័ណ្ណរថយន្តចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន៣៩៧សន្លឹក

- បានវាយតម្លៃសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលគ្រប់លក្ខណៈសម្បត្តិត្រៀមតម្លើងថ្នាក់បៀវត្ស

- បានរៀបចំស្នើគ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា សម្រាប់ពាក់កណ្តាលនីតិកាលទី៤

- បានប្រគល់គ្រឿងឥស្សរិយយស មេដាយការងារជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានស្នាដៃឆ្នើមសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០

- បានបង្កើតគណៈកម្មការដើម្បីពិនិត្យ និងសិក្សាអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពកិច្ចការសុខភាព និងសង្គមកិច្ចនៃព្រឹទ្ធសភា

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន១៦វគ្គ មានសិក្ខាកាមចូលរួមចំនួន២៥៤នាក់ និងសិក្ខាសាលាក្នុងប្រទេសចំនួន០៣លើក មានសិក្ខាកាមចូលរួមចំនួន១៦៦នាក់

- បានទទួលអាហារូបករណ៍ចំនួន២៧កន្លែង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅតាមសាកលវិទ្យាល័យនានា

- បានទទួលអាហារូបករណ៍ចំនួន២៨កន្លែង លើជំនាញ Digital Skill Essential នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ គមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារួមមាន៖ ចំណេះដឹងជំនាញ ភាសាបរទេស ការដឹកនាំ/គ្រប់គ្រង និងបច្ចេកវិទ្យាព័ត៌មាន

- បានស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធ ដើម្បីរៀបចំកសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានធ្វើផែនការសកម្មភាពបណ្តុះបណ្តាលរយៈពេល១០ឆ្នាំ របស់អគ្គលេខាធិការដ្ឋាន

ព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានសង់ឃ្លាំងដាក់សម្ភារ, រៀបការ៉ូបាតបន្ទប់ស្នាក់នៅរបស់មន្ត្រីសេវាកម្ម និងអ្នកបើកបរ, ប្រក់ដំបូលស័ង្កសីដំរថ្វា និងរៀបចំកន្លែង Coffee Counter នៅខាងមុខសាលសិក្ខាសាលាខាងត្បូង, បាំងកញ្ចក់ផ្គងដែកសម្រាប់ធ្វើជាបន្ទប់ប្រជុំ នៅខាងមុខនាយកដ្ឋានស្រាវជ្រាវថវិកា, ធ្វើបញ្ចារថ្មម៉ាបស្លាកឈ្មោះព្រឹទ្ធសភា ដាក់នៅខាងមុខអគារក្រហម ព្រមទាំងបានបំពាក់តុឈើប្រជុំថ្មីបន្ថែមនៅសាលប្រជុំអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១០គ្រឿង

- បានជួសជុល និងគូសគំនូសចំណតរថយន្ត និងសញ្ញាចរាចរណ៍ នៅតាមចំណតនានាក្នុងបរិវេណព្រឹទ្ធសភា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨កន្លែង ស្មើនឹង៥៨លើក និងដាំដើមផ្កាចម្រុះពណ៌នានា ព្រមទាំងដើមឫស្សីក្នុងបរិវេណព្រឹទ្ធសភា២,៧៣០គុម្ព/ដើម

- បានជួសជុល បណ្តាញទឹក ស្តារប្រព័ន្ធលូ ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចគ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១,២២៦គ្រឿង/លើក

- បានជួសជុលនៅតាមសាលប្រជុំ អគារសមាជិកព្រឹទ្ធសភា នាយកដ្ឋាននានា និងត្រួតពិនិត្យសត្វកណ្តៀរ ព្រមទាំងប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើង ការប្រើប្រាស់ទឹក ភ្លើងចំនួន១៣៥លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus និងSetup Window Printer Program Ipad ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៤៧៨គ្រឿងៗ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៥៣៥ប្រធានបទ

- បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន៥៨ក្បាល

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-

លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា ដល់ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២១ **ព្រមទាំង**បានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១,៣៧២ច្បាប់
- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួ៦៦លើក
- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ ចងបដា ពាក្យស្លោក និងចងទង់ជាតិចំនួន៥៨លើក
- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២២ច្បាប់ ស្មើនឹង៦៧៤នាក់, លិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន២៣ច្បាប់ ស្មើនឹង២៣នាក់, លិខិតឧទ្ទេសនាម និងលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មកប្រចាំការនៅពេលបិទខ្ទប់ការធ្វើដំណើរក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ចំនួន១៤៧ច្បាប់ ស្មើនឹងចំនួន៧៤២នាក់
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២,៥៧៥លើក
- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៦៤លើក មានអ្នកចូលរួមចំនួន៣,៨៣៣នាក់
- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣១៣សំណើ
- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន១,៤៣០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥នាក់
- បានថតចម្លងឯកសារចំនួន២៥,២៣៤ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១,៦៥៦ក្បាល អស់ក្រដាសចំនួន១២៤,៨៤២សន្លឹក
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង

ចំនួន៤៩៨លើក ស្មើនឹង១,៨៥៣នាក់ ព្រមទាំងបានបង់ពន្ធផ្លូវរថយន្តសម្រាប់ឆ្នាំ២០២១

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ចំនួន២៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៥លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន១០,៦៨២លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន២៩០លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១២៩លើក

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងទស្សនាវដ្តីចំនួន៦១៧ក្បាល និង ព្រឹត្តិបត្រ កាសែតAKPចំនួន១៥០ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ ដាក់លេខកូដ សៀវភៅ បិទប័ណ្ណខ្នី និងសងសៀវភៅចំនួន១,០៨១ក្បាល

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់ កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៥លើក។

## III-ទិសដៅការងារឆមាសទី២ ឆ្នាំ២០២១

***-បន្តចូលរួមអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលឱ្យម៉ឺងម៉ាត់ ដើម្បីចូលរួមប្រយុទ្ធប្រឆាំង ការរីករាលដាលជំងឺកាចសាហាវកូវីដ-១៩ តាមវិធានការរបស់ក្រសួងសុខាភិបាល។ ចាត់វិធានការ ជាក់ស្តែង ដើម្បីគ្រប់គ្រងការរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងស្ថាប័ន។***

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់ ដូចខាងក្រោមៈ

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ច គ្រប់ជ្រុងជ្រោយតំបន់

២-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨ថ្មី នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

៤-សេចក្តីព្រាងច្បាប់ស្តីពី ការប្រកួតប្រជែង។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារ និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងចូលរួមពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំ និងចូលរួមកិច្ចប្រជុំ និងវេទិកានានា

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

+មហាសន្និបាត (AIPA) លើកទី៤២ (ថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០២១)

+សន្និសីទ (CLV) លើកទី៨ (ថ្ងៃទី២៤-២៥ ខែកញ្ញា ឆ្នាំ២០២១)

+កិច្ចប្រជុំ (ASEP11) (ថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០២១)

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) ដែលអាចចេញដំណើរក្នុងពេលឆាប់ៗនេះ ព្រោះដៃគូ SIDA ភ្នំពេញ និងបាងកក និងSDC បានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយរួចហើយ

-បន្តតាមដានវឌ្ឍនភាពនៃការរៀបចំប្រជុំ វេទិកាសភាអន្តរជាតិនានាដូចជា ASEP11

-ការសហការរៀបចំកិច្ចសន្ទនាស្តីពី ខួប៦៣ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-ចិន តាមប្រព័ន្ធវីដេអូ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-បន្តអនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្វែងរកជំនួយ និងការបណ្តុះបណ្តាលធនធានមនុស្សពីប្រភពដៃគូនានា និងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ IPU, APF, AIPA, ASEP...។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-ការកែសម្រួលការបែងចែកថវិកាជាថ្មី សម្រាប់អនុវត្តឆមាសទី២ ឆ្នាំ២០២១ ក្រោយពីការធ្វើវិចារណកម្មថវិកា

-ត្រៀមរបាយការណ៍ថវិកាឆមាសទី១ និងប្រចាំឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ការកសាងថវិកាឆ្នាំ២០២២ និងការពារគម្រោងថវិកាកម្រិតបច្ចេកទេស និងនយោបាយ

-ត្រៀមរៀបចំបែងចែក និងប្រើប្រាស់ថវិកាឆ្នាំ២០២២ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការកសាងថវិកាតាមកម្មវិធីរបស់អង្គភាពថវិកាចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២២

-ការអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាព ការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្តោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការបានទាន់ពេលវេលា

-បន្តសហការជាមួយក្រុមការងារ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត

បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការបណ្តុះបណ្តាលនឹងមានសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងបរិបទកូវីដ-១៩នេះ និងឆ្នាំខាងមុខ ហើយអាចសម្រេចយុទ្ធសាស្ត្រកៀរគរជំនួយ DO MORE WITH LESS ឬ LESS IS MORE ក្នុងក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា (២០២១-២០៣០)

-បន្តបណ្តុះបណ្តាលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមកម្មវិធីរៀនពីចម្ងាយ

-បន្តការដ្ឋានសំណង់អគារកម្ពស់៣ជាន់ និងសិក្សាកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចូលរួមពិធីបុណ្យជាតិសំខាន់ៗ និងពិធីផ្លូវការផ្សេងៗ។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរ៉ាប់រងការងារលើមុខងារទាំង៥ ជារួមបានទទួលលទ្ធផលល្អប្រសើរ។ ទោះបីស្ថិតក្នុងកាលៈទេសៈលំបាក និងស្មុគស្មាញយ៉ាងណាក៏ដោយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបត់បែនតាមស្ថានភាពជាក់ស្តែងក្នុង

ការផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានដោយរលូន។ ទន្ទឹមនឹងនេះ បានផ្ដោតការយកចិត្តទុកដាក់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាពិសេស ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ បានខិតខំប្រឹងប្រែងប្រែក្លាយបញ្ហាប្រឈមឱ្យទៅជាកាលានុវត្តភាព តាមយន្តការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើគ្រប់វិស័យនៃការងារប្រចាំថ្ងៃ រដ្ឋបាលអេឡិចត្រូនិច និងរៀបចំកិច្ចប្រជុំអន្តរជាតិនានាតាមប្រព័ន្ធវីដេអូទាំងផ្ទៃក្នុងស្ថាប័នក៏ដូចជាក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីធានានិរន្តរភាពការងារឱ្យស្របតាមស្ថានភាពជាក់ស្ដែង និងតម្រូវការចាំបាច់ របស់ស្ថាប័ន និងប្រទេសជាតិ។

សកម្មភាពលេចធ្លោគឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋានតាមរយៈ ការចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់ របស់ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក ការរៀបចំវេទិកា កិច្ចពិគ្រោះយោបល់ ការឈ្វេងយល់អំពីវឌ្ឍនភាពជាវិជ្ជមានក្រោយការរៀបចំវេទិកា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យ នៅថ្នាក់ក្រោមជាតិ។

ដើម្បីឱ្យស្របតាមបរិបទនៃការវិវត្តថ្មី ជាពិសេសការធ្វើវិចារណកម្មថវិកាឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ខិតខំពង្រឹងប្រសិទ្ធភាពចំណាយ ដោយអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្ដោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត។

មន្ត្រីរាជការទាំងអស់ ត្រូវអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ឱ្យបានម៉ឺងម៉ាត់ ព្រមទាំងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ជំងឺកូវីដ-១៩ នៅបន្តជាការគំរាមកំហែងរួមសម្រាប់ពេលខាងមុខនេះ។

ថ្ងៃចន្ទ ៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**